ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

**នាយកដ្ឋានព័ត៌មាន**

# សេចក្តីប្រកាសព័ត៌មាន

តបតាមការអញ្ជើញរបស់ឯកឧត្តម **ប្រាក់ សុខុន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ លោកជំទាវ **ស៊ុសម៉ា ស្វារ៉ាច** រដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋឥណ្ឌា នឹងដឹកនាំគណៈប្រតិភូអញ្ជើញមកបំពេញទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា ពីថ្ងៃទី ២៨ ដល់ ៣០ ខែ សីហា ឆ្នាំ ២០១៨។

ក្នុងអំឡុងពេលទស្សនកិច្ចនៅកម្ពុជា លោកជំទាវ នឹងចូលជួបសម្តែងការគួរសម ជាមួយ**សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា និង**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

លោកជំទាវ **ស៊ុសម៉ា ស្វារ៉ាច** នឹងពិភាក្សាទ្វេភាគីជាមួយឯកឧត្តមទេសរដ្ឋមន្ត្រី **ប្រាក់ សុខុន** អំពីបញ្ហាជាច្រើនទាក់ទងនឹងកិច្ចសហប្រតិបត្តិការទ្វេភាគី ហើយនិងផ្លាស់ប្តូរយោបល់គ្នាអំពីបញ្ហាតំបន់ និងអន្តរជាតិដែលមានការចាប់អារម្មណ៍ដូចគ្នា។

បន្ទាប់ពីជំនួបទ្វេភាគី នឹងមានការចុះហត្ថលេខាលើឯកសារចំនួន៣ ដូចខាងក្រោមៈ

- កិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌា និងរាជរដ្ឋាភិបាលកម្ពុជា សម្រាប់ការអភិរក្ស/ជួសជុលប្រាសាទព្រះវិហារ នៅក្នុងស្រុកជាំក្សាន ខេត្តព្រះវិហារ ប្រទេសកម្ពុជា
- អនុស្សរណៈនៃកិច្ចសហប្រតិបត្តិការរវាងក្រសួងសុខាភិបាល និងកិច្ចការគ្រួសារ នៃសាធារណរដ្ឋឥណ្ឌា និងក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យសុខភាព និងឱសថ
- អនុស្សរណៈនៃការយោគយល់គ្នារវាងវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា និងវិទ្យាស្ថានការបរទេស នៃក្រសួងការបរទេស នៃសាធារណរដ្ឋឥណ្ឌា។

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

លោកជំទាវ **ស៊ុសម៉ា ស្វារ៉ាច** គ្រោងអញ្ជើញទស្សនាប្រាសាទបុរាណមួយចំនួន នៅក្នុងខេត្តសៀមរាប រួមទាំងគម្រោងជួសជុលប្រាសាទតាព្រហ្ម ដែលគាំទ្រដោយរដ្ឋាភិបាលឥណ្ឌា។

ដំណើរទស្សនកិច្ចផ្លូវការនេះ នឹងពង្រឹងថែមទៀតនូវទំនាក់ទំនងមិត្តភាពជាប្រពៃណី និងកិច្ចសហប្រតិបត្តិការជិតស្និទ្ធរវាងកម្ពុជា និងឥណ្ឌា។

ថ្ងៃ សុក្រ ១៣ កើត ខែស្រាពណ៍ ឆ្នាំ ច សំរិទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែសីហា ឆ្នាំ ២០១៨